ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គំរោងជំនួយ
# ផ្នែកព្រហ្មទណ្ឌ
# និងយុត្តិធម៌
# នៅកម្ពុជា
# ដំណាក់កាលទី៣

## គោលការណ៍មូលនិធិបត់បែន

ខែមិនា ឆ្នាំ២០០៨

Australian Government
AusAID

ផ្តល់មូលនិធិដោយទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ

# សេចក្តីផ្តើម

ឯកសារនេះបញ្ជាក់យ៉ាងច្បាស់អំពីគោលការណ៏ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តការ និងការគ្រប់គ្រង មូលនិធិបត់បែន។ ហើយ ឯកសារនេះក៏បានផ្តល់ ផងដែរនូវការពន្យល់សង្ខេបបង្ហាញអំពីសនិទានភាពនៃវត្តមានមូលនិធិបត់បែន ដែលមានន័យថាៈ ឯកសារនេះ ត្រូវតែផ្សារភ្ជាប់ជាមួយគោលការណ៏ណែនាំមូលនិធិបត់បែនដែលមានការ ពន្យល់ល្អិតល្អន់ អំពីគោលការណ៏ និង នីតិវិធីនានាដែលពាក់ព័ន្ធនិងការប្រើប្រាស់មូលនិធិនេះ។

## ប្រវត្តិ

គំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធមិនៅកម្ពុជា ដំណាក់កាលទី៣ (CCJAP III) គឺជាការផ្តួចផ្តើមគំនិតរួមគ្នាមួយរបស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ដែលត្រូវបានផ្តល់ថវិកាតាមរយៈទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៏អន្តរជាតិ (AusAID)។ គោលបំណងនៃគំរោង CCJAP III គឺគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា និង ដៃគូរពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់នូវការទទួលបានភាពយុត្តិធមិ ក្នុងក៏រិតស្តង់ដារខ្ពស់ អោយបានស្មើភាពគ្នា ជាពិសេសគឺផ្តោតទៅលើតម្រូវការរបស់អនីតិជន និងក្រុមជនងាយរងគ្រោះដ៏ទៃទៀត។

មូលនិធិបត់បែន (FSF) គឺជាផ្នែកមួយដ៏សំខាន់របស់គំរោង CCJAP III ដែលត្រូវបានរៀបចំកសាងឡើង ដើម្បីអនុញ្ញាតអោយមាន ការកំណត់បែងចែកមូលនិធិបត់បែននេះ ស្របទៅតាមទិសដៅនានារបស់គំរោង ហើយនិងជួយលើកកំពស់ដល់ការធ្វើសេចក្តីសំរេចចិត្តក្នុងការកំណត់បែងចែកធនធាននេះ តាមរយៈ ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង។

មូលនិធិបត់បែននេះត្រូវបានរៀបចំកសាងឡើងជារួមមានសំរាប់ៈ

- ការផ្តល់មូលនិធិជាអាទិភាពសំរាប់ផែនការប្រចាំឆ្នាំតាមរយៈសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង
- គម្រោងការណ៏ដាក់ពាក្យសុំមូលនិធិ ដើម្បីលើកទឹកចិត្តដល់ដៃគូពាក់ព័ន្ធដែលមិនមែនរដ្ឋាភិបាល និងថ្នាក់ក្រោមជាតិដ៏ទៃទៀត អោយចូលរួមក្នុងសកម្មភាពកសាងតាមវិស័យ និង

- មូលនិធិដែលត្រូវបានទុកសំរាប់តែប្រើប្រាស់ចំពោះយុទ្ធសាស្ត្រសំខាន់ៗប៉ុណ្ណោះ ។

## គោលបំណង និងសនិទានភាព

គោលបំណងនៃគោលការណ៍ណែនាំស្តីពីមូលនិធិបត់បែននេះ គឺដើម្បីផ្តល់នូវការណែនាំសំរាប់ការជ្រើសរើស ការរៀបចំកសាង ការអនុវត្តន៍ និងការពិនិត្យតាមដាន នូវរាល់សកម្មភាពនានា ដែលទទួលបានថវិកាពី មូលនិធិបត់បែននេះ ក្នុងនេះរួមទាំងការងារសាងសង់ផងដែរ ដើម្បីជាប្រយោជន៍ធានាបានថា: សកម្មភាពទាំងនោះគឺ :

- ស្របទៅនឹងគោលដៅ គោលបំណង ទិសដៅ និងគោលគំនិតសំខាន់ៗរបស់គម្រោង ដែលត្រូវ បានកំណត់នៅក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រ
- ដាក់បញ្ចូលនូវបទពិសោធន៍ពីគម្រោង CCJAP ដំណាក់កាលទី២, និង
- ដាក់បញ្ចូលអោយមានការរក្សាសុវត្ថិភាព និងការគ្រប់គ្រងគុណភាពបានសមស្រប ។

## ថវិកាដែលមាន

ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID) បច្ចុប្បន្នគឺជាប្រភពផ្តល់ថវិកាដ៏សំខាន់ សំរាប់គម្រោង CCJAP III ។ មូលនិធិបត់បែននេះ ត្រូវបានរៀបចំអោយមានរចនាសម្ព័ន្ធមួយ ដើម្បីទទួលបាននូវ ថវិកាបន្ថែម ទៀតពីដៃគូអភិវឌ្ឍន៍សំរាប់រាល់សកម្មភាពណាដែលស្របទៅនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រគំរោង CCJAP III ។ ជាឧទាហរណ៍ ទីភ្នាក់ងារ DANIDA បានជ្រើសយកការផ្តល់មូលនិធិដើម្បីគាំទ្រដល់សកម្មភាពកំណែទំរង់ច្បាប់ និងតុលាការ ។ ហើយថវិការបស់ដៃគូអភិវឌ្ឍន៍ នីមួយៗ នឹងត្រូវបានគ្រប់គ្រង និងទូទាត់ការចំណាយដោយឡែកៗពីគ្នា ដើម្បីផ្តល់លទ្ធភាពអោយមាន របាយការណ៍អនុវត្តការងារមួយផ្ទាល់ និងការតាមដានផ្នែកហិរញ្ញវត្ថុ សំរាប់ការប្រើប្រាស់គណនីមូលនិធិ របស់ដៃគូអភិវឌ្ឍន៍ ទាំងនោះ ។

## ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID)

រដ្ឋាភិបាលអូស្ត្រាលី តាមរយៈទីភ្នាក់ងារ អូស្ត្រាលី ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (**AusAID**) បានសន្យាផ្តល់ប្រាក់ ចំនួន ៧,៥លានដុល្លាអូស្ត្រាលី ដល់មូលនិធិបត់បែន ។

មូលនិធិបត់បែននេះត្រូវបានបែងចែកដូចខាងក្រោមនេះ :

- ចំនួន ៤លានដុល្លាអូស្ត្រាលី សំរាប់ការងារសាងសង់
- ចំនួន ៣លានដុល្លាអូស្ត្រាលី សំរាប់ឆ្លើយតបទៅនឹងអាទិភាពនានាដែលមានការពាក់ព័ន្ធក្នុងផែនការប្រចាំឆ្នាំ
- ចំនួនអប្បរមា ៥០០.០០០ដុល្លាអូស្ត្រាលី ដើម្បីគាំទ្រសកម្មភាព/កម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមានការចុះបញ្ជីត្រឹមត្រូវ ។

## ដានីដា (DANIDA)

រដ្ឋាភិបាលដាណឺម៉ាក តាមរយៈដានីដា (DANIDA) បានសន្យាផ្តល់ប្រាក់ ចំនួន ៤.២៩៨.០០០ DK (ប្រហែល ស្មើនឹង ៩៥០.០០០ ដុល្លាអូស្ត្រាលី) ដល់មូលនិធិបត់បែន ។

មូលនិធិនេះមានគោលបំណងគាំទ្រដល់ផ្នែកទី១ និងទី៤ របស់គម្រោង សំរាប់កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ និងសកម្មភាពតុលាការគំរូនៅខេត្តកណ្តាល ។

## ការទទួលបានមូលនិធិ

មានវិធីសាស្ត្រ២ដើម្បីទទួលបានមូលនិធិ:

១. **វិធីសាស្ត្រទី១** ពាក់ព័ន្ធដោយផ្ទាល់ជាមួយមូលនិធិបត់បែនដែលបានដាក់បញ្ចូលទៅក្នុងផែនការប្រចាំឆ្នាំ ដែលអនុម័តដោយ ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ហើយបន្ទាប់មកត្រូវធ្វើរបាយរាយការណ៍ ជូនសមាជិកប្រតិបត្តិរបស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ។

២. **វិធីសាស្ត្រទី២** ពាក់ព័ន្ធទៅនឹងសកម្មភាពដែលទើបកើតឡើង និងគំនិតច្នៃប្រឌិតថ្មី ដែលមិនមាននៅក្នុងផែនការប្រចាំឆ្នាំ ។ រាល់ពាក្យស្នើរសុំមូលនិធិត្រូវបានពិនិត្យនិងវាយតំលៃដោយក្រុមពិនិត្យនិងវាយតំលៃមូលនិធិបត់បែន (សូមមើលតារាងខាងក្រោយ) បន្ទាប់មកដាក់ជូន ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងអនុម័ត ហើយរាយការណ៍ទៅអោយសមាជិកប្រតិបត្តិ របស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ។ វិធីនេះធានាថាមានលក្ខណៈងាយស្រួលដើម្បីទទួលបានមូលនិធិ ។

## វិធីសាស្រ្តទី១ ផែនការប្រចាំឆ្នាំ

ផែនការប្រចាំឆ្នាំ គឺជាដំណើរការមួយដែលមានការសហការ និងមានការចូលរួមពីអ្នកពាក់ព័ន្ធ មកពី តំណាងអង្គការដែលជាដៃគូ ក្រសួង ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ ក្រុមទីប្រឹក្សាពិគ្រោះយោបល់ផ្នែកយុត្តិធមិព្រហ្មទណ្ឌ (CCJAG) AusAID និងមន្ត្រីរបស់ គម្រោង CCJAP ។ ផែនការប្រចាំឆ្នាំនឹង ឆ្លុះបញ្ចាំងនូវគោល ដៅរួមរបស់អ្នកពាក់ព័ន្ធ ហើយធានាថាសកម្មភាពនិង លទ្ធផលរំពឹងទុករបស់ផែនការប្រចាំឆ្នាំ នឹងជួយគាំទ្រដោយផ្ទាល់នូវយុទ្ធសាស្រ្តកំណែទម្រង់ថ្នាក់ជាតិ ។

ឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្រ្តាលីសំរាប់មូលនិធិបត់បែននេះ ត្រូវបានលើកបង្ហាញយ៉ាងច្បាស់នៅក្នុងវិសាលភាពនៃសេវាកម្មរបស់ក្រុមហ៊ុនម៉ៅការគ្រប់គ្រង ។ ដូច្នេះ មូលនិធិបត់បែននេះ នឹងត្រូវបាន ប្រើប្រាស់សំរាប់ ផ្តល់ដល់សកម្មភាព និងធនធានដែលអាចនឹងកើតមានឡើង ហើយដែលមិន ត្រូវបានឆ្លើយតបតាមកញ្ចប់ថវិកាប្រតិបត្តិការរបស់ក្រុមហ៊ុនម៉ៅការគ្រប់គ្រង ប៉ុន្តែជាសកម្មភាព និងធនធានដែលពាក់ព័ន្ធទៅនឹងអាទិភាព ដែលមានគូសបញ្ជាក់ក្នុងផែនការការងារប្រចាំឆ្នាំ ហើយត្រូវបានអនុម័តដោយ ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងរួចហើយ ។ ប្រភេទនៃធនធាន/សកម្មភាពដែលត្រូវផ្តល់ថវិកាអោយ អាចនឹងមាន ដូចជា :

- ក) ការងារសាងសង់ខ្នាតតូច ឬ ខ្នាតមធ្យម រាប់បញ្ចូលទាំងការងារជួសជុល ហើយនិងឧបករណ៍ សំភារៈចាំបាច់ ឬ គ្រឿងសង្ហារឹម (ដែលមានតម្លៃនីមួយៗ រហូតដល់ ១០០,០០០ ដុល្លាអាមេរិក)
- ខ) សម្បទានដល់អង្គការនានា ដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬ អន្តរជាតិ ដែលមានមូលដ្ឋាននៅកម្ពុជា សង្គមស៊ីវិល និងវិជ្ជាស្ថានស្រាវជ្រាវ
- គ) សម្បទានខ្នាតតូច ដល់ស្ថាប័ន/អង្គភាពរាជរដ្ឋាភិបាលកម្ពុជា ដែលមានការប្រព័ន្ធគ្រប់គ្រង ត្រួតពិនិត្យ និងធ្វើសាវនកម្មលើហិរញ្ញវត្ថុជាចាំបាច់ ដើម្បីធានាបាននូវគណនេយ្យភាព និង តម្លាភាព
- ឃ) ជំនួយបច្ចេកទេសរយៈពេលខ្លី, និង
- ង) កសាងសមត្ថភាព និងសកម្មភាពសិក្សា ដែលមិនទាន់បានផ្តល់សំរាប់ថវិកាគោលរបស់គំរោង ។

## ការផ្សារភ្ជាប់ទៅដំណើរការធ្វើផែនការប្រចាំឆ្នាំ

ជាបឋមមូលនិធិបត់បែននឹងផ្តោតទៅលើគំនិតថ្មីប្រឌិតថ្មី ឬបញ្ហាដែលកើតមានឡើង ប៉ុន្តែនៅពេលដែលបញ្ហានោះមានលក្ខណៈល្អប្រសើរឡើងវិញ មូលនិធិដែលនឹងត្រូវប្រើប្រាស់សំរាប់សកម្មភាពមុននោះ អាចយកទៅប្រើប្រាស់សំរាប់សកម្មភាពថ្មីវិញដែលគាំទ្រដោយផ្ទាល់ដល់លទ្ធផលរំពឹងទុករបស់គម្រោង ។

ការបែងចែកមូលនិធិសំរាប់ស្ថាប័នជាតិ និងអង្គការដៃគូរ នឹងបង្កើតបានជាផ្នែកមួយសំខាន់ដល់ដំណើរការធ្វើផែនការប្រចាំឆ្នាំ។ ការបែងចែកបែបនេះ នឹងចេញមកពីការស្នើរសុំរបស់អង្គការដៃគូរសំខាន់ៗ ក្នុងពេលធ្វើផែនការប្រចាំឆ្នាំ ហើយក៏ចេញពីការវាយតំលៃរបស់ក្រុមការងារគម្រោងផងដែរ ចំពោះធនធានដែលតម្រូវអោយមាន ដើម្បីយកមកសំរេច សកម្មភាពដែលបានគ្រោងទុក ។

ចំនួនមូលនិធិភាគច្រើនត្រូវបានរំពឹងថា នឹងត្រូវយកទៅប្រើប្រាស់សំរាប់ផែនការការងារប្រចាំឆ្នាំ ហើយមូលនិធិនេះបាន កំណត់យ៉ាងច្បាស់នៅក្នុងឯកសារផែនការការងារប្រចាំឆ្នាំ។ ដូច្នេះ ដំណើរការនេះត្រូវមាន ការកំណត់អោយបានអោយច្បាស់ សំរាប់ការទូទាត់ចំណាយជាទូទៅរបស់គំរោង ដែលត្រូវបានផ្តល់ថវិកាផ្ទាល់ពី AusAID ហើយនិងសកម្មភាពណាមួយដែលមាន ក្នុងផែនការប្រចាំឆ្នាំ ហើយប្រើប្រាស់ថវិកាដែលបានមកពីមូលនិធិបត់បែននោះ ។ សកម្មភាពនៅក្នុងផែនការការងារប្រចាំឆ្នាំ គួរត្រូវបានបញ្ចូលព័ត៌មានអោយបានគ្រប់គ្រាន់ ដើម្បីផ្តល់នូវភាពសមហេតុផលនៃការប្រើប្រាស់មូលនិធិនេះអោយបានគ្រប់គ្រាន់ នឹងបញ្ជាក់អំពីលទ្ធផលរំពឹងទុកអោយបានច្បាស់លាស់ ។

ជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងនឹងធ្វើការពិនិត្យ និងអនុម័តផែនការប្រចាំឆ្នាំរបស់គម្រោង CCJAP ។ ជាផ្នែកមួយនៃដំណើរការនេះ ផែនការប្រចាំឆ្នាំក៏នឹងគូសបញ្ជាក់អំពីមូលនិធិបត់បែនដែលប្រើប្រាស់ ដើម្បីគាំទ្រ សកម្មភាពនីមួយៗ ហើយនិងដាក់បង្ហាញសកម្មភាពទាំងនោះ សំរាប់សុំអោយមានការអនុលោមភាពផងដែរ ។

ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងនឹងជួបប្រជុំពីរដងក្នុងមួយឆ្នាំ ដើម្បីធ្វើការពិនិត្យពិចារណាទៅលើពាក្យស្នើរសុំមូលនិធិសំរាប់ការដាក់បញ្ចូល/សកម្មភាពដែលអាចកើតមានឡើងក្នុងកំឡុងពេលអនុវត្តផែនការប្រចាំឆ្នាំ ផងដែរ ។

## វិធីសាស្ត្រទី២ ក្រុមពិនិត្យវាយតំលៃមូលនិធិបត់បែន

ដើម្បីធានាថា: មូលនិធិបត់បែននៅតែមានលក្ខណៈបត់បែននោះ ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង បានបង្កើតក្រុមពិនិត្យ និងវាយតំលៃ ដើម្បីធ្វើការពិចារណាលើពាក្យស្នើរសុំមូលនិធិបត់បែន សំរាប់ការដាក់បញ្ចូល/សកម្មភាព

នានា ក្នុងចន្លោះពេលប្រជុំជាផ្លូវការ របស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង។ ហើយក្រុមពិនិត្យនិងវាយតំលៃនេះ នឹងធ្វើការពិនិត្យទៅលើរាល់ពាក្យស្នើរសុំមូលនិធិ ហើយ ផ្តល់អនុសាសន៍ជូនប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង ដើម្បីអនុម័ត ឬមិនអនុម័ត។ បន្ទាប់មក ប្រធានក្រុមប្រឹក្សាភិបាលជាតិ នឹងរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង នៅពេលប្រជុំខាងមុខ។

ក្រុមត្រួតពិនិត្យនិងវាយតំលៃនេះ នឹងជួបប្រជុំយ៉ាងហោចណាស់ម្តងក្នុងចន្លោះពេលការប្រជុំរបស់ក្រុមប្រឹក្សាភិបាលជាតិ ហើយក៏អាចជួបប្រជុំនៅពេលដែលចាំបាច់។

## ការប្រើប្រាស់រចនាសម្ព័ន្ធជាតិ និងថ្នាក់ក្រោមជាតិ

គោលការណ៍សំខាន់នៃកម្មវិធីជំនួយរបស់អូស្ត្រាលី គឺជាជំនួយដែលមានកិច្ចព្រមព្រៀងរួម និងអនុវត្តន៍ជាមួយដៃគូប្រទេសកំពុងអភិវឌ្ឍន៍។ ដូច្នេះ កម្មវិធីជំនួយនេះនឹងនៅតែបន្ត ប៉ុន្តែថែមទាំងនឹងធ្វើអោយប្រសើរឡើងទៀត។ តាមបទពិសោធន៏បានបង្ហាញថាៈ កម្មវិធីជំនួយនេះ ស្របទៅនឹងអាទិភាពរបស់រដ្ឋាភិបាលជាដៃគូ ហើយត្រូវបានរក្សាគាំទ្រដោយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងមានការចូលរួមពីអ្នកទទួលផល ក្នុងការរៀបចំ និងអនុវត្តស្របទៅនិងថវិការបស់រដ្ឋាភិបាលដៃគូ និងប្រព័ន្ធនានា ដែលទំនងជាមាននិរន្តរភាព និងប្រសិទ្ធិភាពជាងកម្មវិធីដែលគ្មានលក្ខណៈទាំងអស់នោះ។ ដូច្នេះ កម្មវិធីជំនួយនេះ ទាមទារអោយមានការ ពន្លឿនបំលាស់ដូរ មធ្យោបាយបំពេញការងាររួមគ្នាអោយបានច្រើនឡើងថែមទៀត និងមានការរៀបចំចាត់ចែងការអនុវត្តន៍ផ្សេងពីគ្នា ដែលកិច្ចការទាំងពីរ នេះហើយដែលកម្មវិធីជំនួយនេះបានចាប់ផ្តើមអនុវត្តនៅឆ្នាំ កន្លងមកថ្មី១នេះ[១]។

ក្នុងរយៈពេលនៃឆ្នាំដំបូងនៃប្រតិបត្តិការរបស់មូលនិធិបត់បែននេះ គម្រោង CCJAP នឹងធ្វើការងសិក្សាស្រាវជ្រាវវិភាគអំពីឳកាសនានាសំរាប់បន្សុំធាតុផ្សំនៃការដាក់ពាក្យស្នើសុំសម្បទានមូលនិធិបត់បែន ចូលទៅក្នុងប្រព័ន្ធជាតិ និង ថ្នាក់ក្រោមជាតិ ដែលមានរាប់បញ្ចូលទាំងៈ

- ការពិនិត្យអំពីរចនាសម្ពន្ធ័វិមជ្ឈការ និងវិសហមជ្ឈការ
- ធ្វើការជាមួយរចនាសម្ពន្ធ័រាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ជាមួយខេត្តដែលក្នុងនោះមានរាប់បញ្ចូលទាំងក្នុងតំបន់ប្រតិបត្តិការរបស់គំរោង CCJAP ដែរ, និង

[១] ជំនួយអូស្ត្រាលី ៖ ការលើកកំពស់កំណើន និងស្ថេរភាព ៖ ឯកសារជំនួយអន្តរជាតិ (White Paper) ស្តីពីកម្មវិធីជំនួយបរទេសរបស់រដ្ឋាភិបាលអូស្ត្រាលី

- ស្វែងរកការអភិវឌ្ឍន៍ដែលកើតមានឡើងក្នុងប្រព័ន្ធ និងក្នុងក្រសួងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលអាចជាការបង្ហាញនូវឱកាសជាសក្តានុពលមួយសំរាប់ ការដាក់បញ្ចូលក្នុងគំរោងការដាក់ពាក្យស្នើសម្បទានមូលនិធិបត់បែននោះ ។

## ការងារសាងសង់

ដំណើរការកំណត់បែងចែកថវិកាសំរាប់ការងារសាងសង់ គឺធ្វើដូចគ្នាទៅនឹងការកំណត់បែងចែកថវិកាពី មូលនិធិបត់បែនដែរ ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ការងារសាងសង់មានលក្ខខ័ណ្ឌ និងការគាំទ្របន្ថែមទៀត ដោយសារតែមានវាពាក់ព័ន្ធដល់ ភាពចំរុះនៃហានិភ័យ ហើយបញ្ហានេះត្រូវបានលើកឡើងបង្ហាញលំអិតក្នុងឧបសម្ព័ន្ធ A ។

ផ្នែកនីមួយៗរបស់គំរោងត្រូវរៀបចំ **"បញ្ជីអនុវត្តការងារ"** ដោយផ្អែកលើអាទិភាពក្នុងផែនការការងារប្រចាំឆ្នាំនៃឆ្នាំបច្ចុប្បន្ន ។ ក្នុងនោះមានប្រភេទនៃការងារសាងសង់ ដែលសមស្របសំរាប់គាំទ្រដល់គោលដៅ និងគោលបំណងរបស់គំរោង និងគោលគំនិតសំខាន់ៗរបស់គំរោង ព្រមទាំងទិសដៅតាមផ្នែក ។

នៅតាមផ្នែកនីមួយៗរបស់គំរោង នឹងមានកំរិតជាក់លាក់ដល់ការកំណត់បែងចែកថវិកា ដើម្បីធានាបានថារាល់ផ្នែកទាំងអស់ទទួលបានការកសាងសមត្ថភាព និងការអនុវត្តន៍ ក្នុងការបំពេញការងារប្រភេទនេះ ។ តែទោះយ៉ាងនេះក្តី ថវិកាដែលមានចំនួនច្រើន នឹងត្រូវបានដាក់អោយដេញថ្លៃប្រកួតប្រជែងដោយទីភ្នាក់ងារនានា ដោយមានតែសំណើដែលមានគុណភាពប៉ុណ្ណោះ អាចស្ថិតក្នុងលក្ខណៈវិនិច្ឆ័យសំរាប់ការផ្តល់ថវិកា ។ ការជ្រើសរើសអ្នកផ្តល់សេវាការងារសាងសង់ នឹងត្រូវបានធ្វើឡើងដោយឈរលើដំណើរការចំហរ និង មានតម្លាភាពស្របតាមគោលការណ៍ណែនាំស្តីពីការផ្គត់ផ្គង់របស់ច្បាប់ Commonwealth នៃប្រទេសអូស្ត្រាលី ។

## ប្រតិបត្តិការការងារសាងសង់

ភាគច្រើននៃការងារសាងសង់ត្រូវបានរំពឹងថា នឹងធ្វើឡើងនៅក្នុងឆ្នាំទី២ ទី៣ និងទី៤ ។ ឆ្នាំទីមួយ នឹងត្រូវចំណាយទៅលើការរៀបចំ ប៉ុន្តែ នឹងដាក់បញ្ចូលនូវគំរោងដែលជ្រើសរើសពី៨ ទៅ១០ ដើម្បីសាកល្បងប្រព័ន្ធនេះ ។ ឆ្នាំទី៥ នឹងផ្តោតយកចិត្តទុកដាក់លើការរៀបចំត្រៀមបញ្ចប់សកម្មភាពនានា ប្រមូលចងក្រងបទពិសោធន៍ និងអនុវត្តយុទ្ធសាស្ត្របញ្ចប់គំរោង ។ នៅឆ្នាំនីមួយៗ នឹងត្រូវបានចែកចេញជាពីរដំណាក់កាល រួមមាន: ដំណាក់កាល ទី១

ជ្រើសរើស ធ្វើផែនការ និងរៀបចំកសាងប្លង់ក្នុងរដូវវស្សា និងដំណាក់កាលទី២ ការងារសាងសង់ចាប់ផ្តើមក្នុងរដូវប្រាំង ។

ក្រៅពីការផ្តល់មូលនិធិបត់បែន កម្មវិធីការងារសាងសង់នឹងត្រូវបំពេញការងារជួយដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយការងារសាងសង់អោយបានទូលំទូលាយ ដើម្បីជួយធានាបានថារាល់ការចំណាយលើការងារសាងសង់ មិនគ្រាន់តែបានមកពីមូលនិធិបត់បែនទេ តែវាស្របគ្នាទៅនឹងគោលនយោបាយ និងអាទិភាពរបស់រាជរដ្ឋាភិបាលផងដែរ ។ ជំហានទីមួយនៃដំណើរការនេះ គ្រាន់តែជាការបង្កើតឡើងនៃបញ្ជីអនុវត្តការងារ ។ ជំហានបន្តបន្ទាប់ទៀត អាចមានរាប់បញ្ចូលទាំងសវនកម្មលើមូលនិធិ ដែលកំណត់អំពីទំហំនៃដំណើរការ និងចិរភាពសំរាប់សារពើភ័ណ្ឌសរុបនៃទ្រព្យសម្បត្តិសំណង់ និងផែនការសំរាប់ទាំងការរីកចំរើន ទាំងការរក្សានូវប្រព័ន្ធ ។

## អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល និង សហគមន៍

ពាក្យស្នើសុំពីអង្គការតាមសហគមន៍ (CBO) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGO) នឹងត្រូវបានលើកទឹកចិត្ត ជាពិសេស បើសិនអង្គការទាំងនេះបានបង្ហាញអំពីប្រវត្តិទទួលបានយោគជ័យកន្លងមក ក្នុងការអនុវត្តសកម្មភាពលើវិស័យយុត្តិធម៌ ។ អង្គការតាមសហគមន៍ (CBO) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGO) ត្រូវបង្ហាញថា ខ្លួនមានរចនាសម្ព័ន្ធគ្រប់គ្រងនៅនឹងកន្លែង ហើយនិងមានតំណាងនៅទីនោះ ។

ជានិច្ចកាល អង្គការតាមសហគមន៍ (CBO) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGO) តម្រូវអោយមានការជួយគាំទ្រដល់ការអនុវត្តសកម្មភាពពាក់ពន្ធ័ការងារយុត្តិធម៌ព្រហ្មទណ្ឌ ។ ដូច្នេះការរៀបចំដៃគូរជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (INGO) ឬ ស្ថាប័នសាធារណៈ គឺជាលក្ខខ័ណ្ឌតម្រូវអោយមានចំពោះអង្គការតាមសហគមន៍ (CBO) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGO) ដើម្បីអោយមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់សំរាប់ការស្នើសុំថវិកាពីមូលនិធិបត់បែន ។

មូលនិធិខ្នាតតូច ត្រូវបានបង្កើតដើម្បីលើកទឹកចិត្តអោយអង្គការមិនមែនរដ្ឋាភិបាលចូលរួម ។

## ដំណើរការផ្តល់មូលនិធិបត់បែន

ការគ្រប់គ្រងមូលនិធិបំរុងដែលមានទំហំធំដូចជាមូលនិធិបត់បែននេះ តម្រូវអោយមានការគ្រប់គ្រងត្រឹមត្រូវ ហើយដំណើរការប្រើប្រាស់មូលនិធិត្រូវមានការពន្យល់អោយបានច្បាស់លាស់ដើម្បីធានាថា: មិនមានឧបសគ្គក្នុង ការទទួលបានមូលនិធិ។ គម្រោង CCJAP នឹងរៀបចំវគ្គបណ្តុះបណ្តាលសំរាប់អ្នកស្នើរសុំមូលនិធិ ពីការរៀបចំសំណើរ ដំណើរការជ្រើស រើស និងរបាយការណ៍ហិរញ្ញវត្ថុ។

ឯកសារមូលនិធិបត់បែន នឹងត្រូវពិនិត្យនិងកែសម្រួល ដើម្បីធានាអោយមានគណនេយ្យភាព និងភាពទទួលបានមូលនិធិ។

គោលការណ៍ណែនាំទូទៅស្តីពីនីតិវិធីមូលនិធិបត់បែនមានបង្ហាញនៅតារាងខាងក្រោម:

១. វិធីសាស្ត្រទី១ ពាក់ព័ន្ធដោយផ្ទាល់ជាមួយមូលនិធិបត់បែនដែលបានដាក់បញ្ចូលទៅក្នុងផែនការប្រចាំឆ្នាំ ដែលអនុម័តដោយប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង។

២. វិធីសាស្ត្រទី២ ពាក់ព័ន្ធទៅនឹងសកម្មភាពដែលទើបកើតឡើង និងគំនិតច្នៃប្រឌិតថ្មីដែលមិនមាននៅក្នុងផែនការប្រចាំឆ្នាំ ហើយធានាថាមានភាពងាយស្រួលក្នុងដំណើរការផ្តល់មូលនិធិ។

គម្រោងចំណាយបន្ទាប់ពីការអនុម័ត និងដំណើរការត្រួតពិនិត្យនិងវាយតំលៃមានពន្យល់លំអិតនៅក្នុងគោលការណ៍ណែនាំមូលនិធិបត់បែន។

## សន្និដ្ឋាន

មូលនិធិបត់បែនរៀបចំឡើងដើម្បីធានាពីភាពជាម្ចាស់របស់រាជរដ្ឋាភិបាលនិងដើម្បីពង្រឹងភាពជាដៃគូរជាមួយនិងគម្រោង CCJAP III ។ មូលនិធិបត់បែនគឺជាមូលនិធិដ៏សកម្មមួយដែលតម្រូវអោយមានការប្រែប្រួលទៅតាមតម្រូវការនិងគាំទ្រទិសដៅរបស់គម្រោង។ ដើម្បីបានការអនុម័តពីក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង អ្នកស្នើសុំមូលនិធិ ត្រូវបង្ហាញពីការរីកចំរើនតាមរយៈផលប្រយោជន៍ដែលផ្តល់ដល់ស្ថាប័ននិងមាននិរន្តរភាព។


ការបញ្ចូល FSF ទៅក្នុងសេចក្តីព្រាង ផែនការប្រចាំឆ្នាំ
AusAID
ផែនការប្រចាំឆ្នាំដែលប្រើប្រាស់ FSF អនុលោមដោយ AusAID ហើយបញ្ជូនមកប្រធានNMB
ប្រធានNMB
•ប្រធានលេខាធិការដ្ឋានដាក់ពាក្យស្នើរសុំFSF ដើម្បីសុំការអនុម័តពីប្រធានNMB
• ប្រធានNMB អនុម័ត/មិនអនុម័ត
ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង
ជូនដំណឹង និង របាយការណ៍ស្តីពីការវិវត្តន៍
គំនិតច្នៃប្រឌិតថ្មី/បញ្ហាដែលកើតឡើង/គាំទ្រលទ្ធផលរំពឹងទុក
•ពាក្យស្នើសុំដើម្បីគាំទ្រគំនិតថ្មី កាលានុប្បវត្តន៍ដែលកើតឡើង/ គាំទ្រលទ្ធផលរំពឹងទុកដែលនៅក្រៅ ផែនការប្រចាំឆ្នាំ
•សំណើដែលសុំដោយទីប្រឹក្សានិង ដៃគូររដ្ឋាភិបាល
•សំណើដែលបានរៀបចំនិងដាក់សុំ ដោយទីប្រឹក្សាគំរោងCCJAP និងដៃគូរដ្ឋាភិបាល
លេខាធិការដ្ឋាននៃNMB
ក្រុមវាយតំលៃពាក្យស្នើសុំមូលនិធិបត់បែន
•ប្រធានៈ ប្រធានPMU
•ក្រុមការងារៈ មានសមាជិកNMB យ៉ាងតិច៤រូប. AusAID, ប្រធានលេខាធិការដ្ឋាននៃNMB
•វាយតំលៃលើពាក្យសុំមូលនិធិ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យរបស់មូលនិធិបត់បែន
•ផ្តល់យោបល់លើពាក្យសុំមូលនិធិដល់ប្រធានNMB